May 2007
Khmer *(HP940)*

# សន្លឹកព័ត៌មាន – ព័ត៌មានទូទៅ

(មានបកប្រែចេញជាភាសាឯទៀត)

## តើជម្ងឺមហារីកដោះជាអ្វី?

ជម្ងឺមហារីកដោះគឺជាក្រុមនៃកោសិកាមិនប្រក្រតីដែលចេះតែលូតលាស់ ហើយធំឡើងៗ។ នៅពេលណាមួយ កោសិកាទាំងនេះអាចបង្ករូបរាងជាដុំគ្រាប់នៅក្នុងដោះ។ ប្រសិនបើជម្ងឺមហារីកមិនបានគេកាត់ចោល ឬបង្ក្រាបទេនោះ កោសិកាជម្ងឺមហារីកអាចឆ្លងរាលដាលទៅផ្នែកដទៃទៀតនៃរាងកាយ ហើយនៅពេលណាមួយអាចបណ្តាលឲ្យស្លាប់។

## តើខ្ញុំឋិតនៅក្នុងសភាពគ្រោះថ្នាក់ឬទេ ពីការធ្វើរោគវិនិច្ឆ័យឃើញថាមានជម្ងឺមហារីកដោះ?

ស្ត្រីអូស្ត្រាលី១នាក់ ក្នុងចំណោម៨នាក់នឹងកើតមានជម្ងឺមហារីកដោះនៅក្នុងជីវិតរស់នៅរបស់គេ។

**កត្តាដែលមានគ្រោះថ្នាក់សំខាន់បំផុតចំពោះជម្ងឺមហារីក គឺក្នុងភាពជាស្ត្រីដែលមានអាយុពី៥០ឆ្នាំឡើងទៅ។**

## តើការថតឆ្លុះមើលដោះដោយប្រើកាំរស្មីអ៊ិក្សជាអ្វី?

ការថតឆ្លុះមើលដោះដោយប្រើកាំរស្មីអ៊ិក្ស គឺជាការថតឆ្លុះមើលដោះស្ត្រីដែលប្រើកាំរស្មីអ៊ិក្សកម្រិតទាប ក្នុងស្ត្រីដែលបើពុំដូច្នោះទេ គ្មានភាពមិនប្រក្រតី ឬការប្រែប្រួលដោះទេ។ ការថតឆ្លុះមើលដោះរកឃើញនូវ៩០ភាគរយនៃជម្ងឺមហារីកដោះ ហើយអាចរកឃើញជម្ងឺមហារីកដោះដែលវានៅតូចពេកពុំអាចនឹងស្ទាបដឹង។ **ការរកឃើញបានមុនពេលល្អ គឺជាការការពារយ៉ាងល្អបំផុតសំរាប់អ្នក។** ការរកឃើញជម្ងឺមហារីកបានទាន់ពេលល្អ ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការព្យាបាលដែលប្រកបដោយជោគជ័យ។

## តើខ្ញុំត្រូវទៅថតឆ្លុះមើលដោះញឹកញាប់យ៉ាងណាដែរ?

ថតឆ្លុះមើលដោះចំនួនពីរឆ្នាំម្តងជាទៀងទាត់ ត្រូវបានស្នើសុំសំរាប់ស្ត្រីដែលមានអាយុ៥០ឆ្នាំឡើងទៅ។ ក៏ប៉ុន្តែក្នុងកាលៈទេសៈខ្លះ ការថតឆ្លុះមើលដោះមួយឆ្នាំម្តង អាចត្រូវគេស្នើសុំឲ្យធ្វើឡើងផងដែរ។

## តើការថតឆ្លុះមើលដោះធ្វើឡើងដោយឥតគិតថ្លៃឬ?

BreastScreen WA បានទទួលថវិកាពីរដ្ឋាភិបាលដើម្បីផ្តល់ការថតឆ្លុះមើលដោះ**ដោយឥតគិតថ្លៃ** ធ្វើឡើងរវាងពីរឆ្នាំម្តងដល់ស្ត្រីដែលមានអាយុចាប់ពី៥០ឆ្នាំ ទៅ៦៩ឆ្នាំ។ ស្ត្រីដែលមានអាយុ៤០ឆ្នាំ ទៅ៤៩ឆ្នាំ ហើយលើសពី៧០ឆ្នាំ អាចទទួលការថតឆែកមើលដោះតាមការស្នើសុំទៅ BreastScreen WA។ ការថតឆ្លុះមើលដោះមិនមានសំរាប់ស្ត្រីដែលមានអាយុនៅក្រោម៤០ឆ្នាំទេនៅ BreastScreen WA។

## តើខ្ញុំអាចទទួលការថតឆ្លុះមើលដោះនៅកន្លែងណា?

BreastScreen WA មានកិច្ចបំរើថតឆ្លុះមើលដោះនៅតាមជាយក្រុងចំនួន៧កន្លែងដែលមានទីតាំងនៅ Cannington, Fremantle, Joondalup, Midland, Mirrabooka, ទីក្រុង Perth (ភើត៍) និង Rockingham ហើយនិងកិច្ចបំរើចល័តចំនួនបួនដែលទៅដល់ក្រុងតាមជនបទចំនួន២ឆ្នាំម្តង។

## តើនឹងមានអ្វីកើតឡើងនៅពេលខ្ញុំទៅជួប **BreastScreen WA**?

ពេលណាអ្នកទៅជួបកិច្ចបំរើថតឆ្លុះមើលដោះ BreastScreen WA នោះគេនឹងណែនាំឲ្យអ្នក**ស្លៀកពាក់សំលៀកបំពាក់ពីរផ្នែកដូចជាសំពត់ហ៊ូប ឬខោ ហើយនិងអាវធម្មតា ហើយឲ្យចៀសវាងផងដែរដោយកុំប្រើម្សៅលាបខ្លួន ឬថ្នាំបំបាត់ក្លិនអាក្រក់។** កាលណាអ្នកទៅដល់ BreastScreen WA ដំណើរការដូចតទៅនេះនឹងកើតមានឡើង:

1. អ្នកនឹងត្រូវគេស្វាគមន៍ ហើយស្នើសុំឲ្យបំពេញព័ត៌មានផ្ទាល់ខ្លួន និងហ្វ៊មអនុញ្ញាតយល់ព្រមមួយ។
2. កាលណាអ្នកបានផ្លាស់រ៉ូបរួចហើយ អ្នកថតស្ត្រីម្នាក់នឹងនាំអ្នកទៅកាន់បន្ទប់ថតដោយប្រើកាំរស្មីអ៊ិក្ស ហើយសួរអ្នកនូវសំនួរខ្លះៗ។ បន្ទាប់មកគាត់នឹងចាប់ថតដោះម្ខាងៗ ដោយប្រើកាំរស្មីអ៊ិក្សពីរលើក។
3. អ្នកនឹងត្រូវគេប្រាប់ឲ្យនៅរង់ចាំរហូតទាល់តែអ្នកថតបានឆែកមើលការថតដោយកាំរស្មីអ៊ិក្សទាំងនោះដើម្បី ឲ្យបានដឹងអំពីគុណភាពបច្ចេកទេស។
4. អ្នកថតនឹងប្រាប់ឲ្យអ្នកបានដឹងអំពីពេលណាដែលការពិនិត្យបានធ្វើចប់សព្វគ្រប់ រួចមកអ្នកអាចចេញទៅបាន។
5. ការថតដោយកាំរស្មីអ៊ិក្សរបស់អ្នក នឹងត្រូវបានគេពិនិត្យមើលឡើងវិញ យ៉ាងហោចណាស់ដោយវេជ្ជបណ្ឌិតពីររូបដែលមានការហ្វឹកហ្វឺនជាពិសេស ហើយលទ្ធផលនឹងត្រូវគេផ្ញើទៅអ្នកក្នុងរវាង១៤ថ្ងៃធ្វើការ។
6. វាមិនមែនជាការខុសប្លែកធម្មតាទេ សំរាប់ស្ត្រីដែលត្រូវគេហៅឲ្យត្រឡប់មកវិញសំរាប់ការថតដោយកាំរស្មីអ៊ិក្សបន្ថែម។ ប្រសិនបើការនេះចាំបាច់ គិលានុប្បដ្ឋាកស្នង់ប៉ាន់ដោះមកពី BreastScreen WA នឹងទូរស័ព្ទពិភាក្សារឿងនេះជាមួយអ្នក។

## តើការថតឆ្លុះមើលដោះត្រូវធ្វើដោយរបៀបណា?

ដោះត្រូវបានគេដាក់ដោយប្រុងប្រយ័ត្នឲ្យចំកន្លែងលើម៉ាស៊ីនថតប្រើកាំរស្មីអ៊ិក្ស ហើយសង្កត់ចំនួនពីរបីវិនាទី ក្នុងកាលការថតប្រើកាំរស្មីអ៊ិក្សកំពុងប្រព្រឹត្តទៅ។ ការថតប្រើកាំរស្មីអ៊ិក្សពីរដងត្រូវគេធ្វើសំរាប់ដោះម្ខាងៗ មួយសំរាប់ផ្នែកដោះខាងលើ ហើយមួយទៀតពីចំហៀងដោះ។ ការសង្កត់អាចតឹង ហើយមិនស្រួលឈឺបន្តិចបន្តួច ក៏ប៉ុន្តែមិនមែនឈឺខ្លាំងទេ ទោះជាយ៉ាងណាក្តី ការសង្កត់គឺសំខាន់ណាស់ដើម្បីថតឲ្យបានឃើញរូបដោះច្បាស់បំផុត *(សូមមើលរូបភាពខាងស្តាំខាងក្រោម)* ហើយចំនួនចំហាយវិទ្យុសកម្មកំរិតទាបបំផុតត្រូវគេប្រើ។






*ដោយគ្មានការសង្កត់ទេនោះ ការថតកាំរស្មីអ៊ិក្សរបស់អ្នកមុខជាមើលទៅឃើញព្រិល។*

*ដោយមានការសង្កត់ ការថតកាំរស្មីអ៊ិក្សរបស់អ្នកមើលទៅឃើញច្បាស់* ***ច្រើនផងណាស់***

## ហេតុអ្វីបានជាខ្ញុំត្រូវទៅកន្លែងថតឆ្លុះមើលដោះ?

**ការរកឃើញបានមុនពេលល្អ គឺជាការការពារយ៉ាងល្អបំផុតសំរាប់អ្នក។** ការថតឆ្លុះមើលដោះ អាចជួយសង្គ្រោះជីវិតរបស់អ្នក។

## ការណាត់ពេលជួបអាចធ្វើឡើង ដោយទូរស័ព្ទលេខ **13 20 50**

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទកិច្ចបំរើបកប្រែភាសាសរសេរ និងភាសានិយាយ (TIS) ជាមុន តាមទូរស័ព្ទលេខ 13 14 50 រួចស្នើសុំឲ្យគេតភ្ជាប់អ្នកទៅ BreastScreen WA កិច្ចបំរើទទួលការណាត់ពេលជួប លេខ 13 20 50។

## ការណាត់ពេលជួបជាក្រុម

ការណាត់ពេលជួបជាក្រុមមានផ្តល់សំរាប់ស្ត្រីដែលចូលចិត្តទៅជាក្រុម។ ឧទាហរណ៍ ស្ត្រីដែលនិយាយភាសាដូចគ្នា ស្ត្រីនៅក្នុងក្លិប ឬសមាគម ឬមិត្តភក្តិដែលយល់ឃើញងាយស្រួលជាងក្នុងការណាត់ពេលជួបជាក្រុម។ ចំពោះចម្លល់បន្ថែមទៀតអំពីការណាត់ពេលជួបជាក្រុមសូមទូរស័ព្ទលេខ 13 20 50។

## ប្រភពព័ត៌មានផ្តល់ជូនដោយឥតគិតថ្លៃ

មានកូនសៀវភៅព័ត៌មានមួយចំនួនផ្តល់ជូនដោយឥតថ្លៃ ដែលអ្នកអាចទទួលយកបានអំពីការថតឆ្លុះមើលដោះ ជម្ងឺមហារីកដោះ ស្ត្រីមានប្រវត្តិគ្រួសារដែលមានជម្ងឺមហារីកដោះ ការផ្សាំដោះ ការឈឺដោះ ស្ត្រីដែលមានពិការភាព និងជាច្រើនទៀត។

**ប្រភពព័ត៌មានដែលមាននៅក្នុងភាសាដទៃទៀត**

‘For Me and My Family’*[សំរាប់ខ្ញុំ និងគ្រួសាររបស់ខ្ញុំ]* (ខ្សែវីឌីអូ) មាននៅក្នុងភាសា អារ៉ាប់ ចិនកន្តាំង ក្រូអេហ្ស៊ីន អង់គ្លេស ក្រេក អ៊ីតាលី ខ្មែរ ម៉ាសេដូន រ៉ុស្ស៊ី ប៉ូឡូញ ស៊ើប៊ៀន អេស្បាញ៉ុល តាហ្គាឡុក ទួកគី និងវៀតណាម។

‘Information – Fact Sheet’’ *[សន្លឹកព័ត៌មាន – ព័ត៌មានទូទៅ]* នេះមាននៅក្នុងភាសាអង់គ្លេស អាមហារិច អារ៉ាប់ បូសនៀ ភូមា ចិន ក្រូអេហ្ស៊ីន ដារី ហ្វាស៊ី ក្រេក ឥណ្ឌូណេស៊ី អ៊ីតាលី ម៉ាសេដូន ម៉ាឡេស៊ី ម៉ល់ទី ហូឡង់ ខ្មែរ កូរ៉េ ប៉ូឡូញ ព័រទុយហ្គេ ស៊ើប៊ៀន សូម៉ាលី អេស្ប៉ាញ៉ុល ស្វាហ៊ីលី តាហ្គាឡុក ថៃ ទីហ្គ្រីគណា និងវៀតណាម។

សន្លឹកព័ត៌មាន ‘After your screening mammogram – What next?’ *[បន្ទាប់ពីការថតឆ្លុះមើលដោះហើយ – តើបន្ទាប់មកមានអ្វីទៀត?]* មាននៅក្នុងភាសាអង់គ្លេស អារ៉ាប់ បូសនៀ ចិន ក្រូអេហ្ស៊ីន ដារី ក្រេក ឥណ្ឌូណេស៊ី អ៊ីតាលី ម៉ាសេដូន ម៉ាឡេស៊ី ប៉ូឡូញ ព័រទុយហ្គេ ស៊ើប៊ៀន អេស្ប៉ាញ៉ុល និងវៀតណាម។

‘Screening Mammography for Women with a Family History of Breast Cancer’ *[ការថតឆ្លុះមើលដោះសំរាប់ស្ត្រីមានប្រវត្តិគ្រួសារដែលមានជម្ងឺមហារីកដោះ] មាននៅក្នុងភាសាអង់*គ្លេស បូសនៀ ចិន ដារី ម៉ាឡេស៊ី ស៊ើប៊ៀន និងវៀតណាម។

**ដើម្បីស្នើសុំសន្លឹកព័ត៌មានទាំងឡាយ សូមទូរស័ព្ទលេខ 9323 6762 ឬអ៊ីម៉េល** **[breastscreenwa@health.wa.gov.au](mailto:breastscreenwa@health.wa.gov.au)**